អាជ្ញាធរមីន

C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍

# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

# នៅខែឧសភា ឆ្នាំ២០២៣

## សាវតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

## ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### 1- ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែឧសភា ឆ្នាំ២០២៣

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែឧសភា ឆ្នាំ២០២៣ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥.០២៤នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.១៧៥នាក់(៧៩%) និងស.ផ.ស. ១៣.៨៤៩នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩.៨២០នាក់(៣០%) របួស ៣៦.១២០នាក់(៥៦%) និងពិការអវយវៈ ៩.០៨៤នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២.៦៦៤នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.១១០នាក់(៩%) ស្ត្រី ៤.៧៩៤នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩៣នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)

### 2- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៣

ចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៣ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ១៧ករណី។ តួលេខនេះបានថយចុះ ៣២% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២២ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៥ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ១៧ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ៨ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ៩ករណី។

### 3- ជនរងគ្រោះពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៣

តួលេខជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៣ មានចំនួន ១៩នាក់។ តួលេខនេះបានថយចុះ ៥១% បើប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២២ ដែលមានជនរងគ្រោះចំនួន ៣៩នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ១៩នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ៨នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១១នាក់
- ជនរងគ្រោះស្លាប់ ២នាក់ របួស ១១នាក់ និងពិការអវយវៈ ៦នាក់
- ជនរងគ្រោះជាបុរស ១៤នាក់ ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៤នាក់ និងស្ត្រី ១នាក់។

## 4- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែឧសភា ឆ្នាំ២០២៣

នៅខែឧសភា ឆ្នាំ២០២៣ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៨ករណី ក្នុងនោះគ្រោះថ្នាក់ដោយសារមីន ៥ករណី និងដោយសារស.ផ.ស. ៣ករណី ដែលបានកើតឡើងនៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង។ តួលេខនេះបានកើនឡើង ១០០% បើប្រៀបធៀបជាមួយនឹងខែឧសភា ឆ្នាំ២០២២ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ ៤ករណី។

ព័ត៌មានពីតំបន់គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែឧសភា ឆ្នាំ២០២៣ ដូចខាងក្រោម៖

- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន កើតឡើងនៅលើដីមិនមានការប្រើប្រាស់ ៣ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន កើតឡើងនៅលើដីចម្ការ ២ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. កើតឡើងនៅក្នុងភូមិ ១ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. កើតឡើងនៅលើដីស្រែ ១ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. កើតឡើងនៅក្បែរមានស្ទឹង ១ករណី

## 5- ជនរងគ្រោះក្នុងខែឧសភា ឆ្នាំ២០២៣

នៅខែឧសភា ឆ្នាំ២០២៣ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៧នាក់។ តួលេខនេះបានកើនឡើង ៤០% បើប្រៀបធៀបនឹងខែឧសភា ឆ្នាំ២០២២ ដែលមានជនរងគ្រោះ ៥នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ៧នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ៥នាក់ និងដោយសារស.ផ.ស. ២នាក់
- ជនរងគ្រោះស្លាប់ ១នាក់ របួស ៤នាក់ និងពិការអវយវៈ ២នាក់
- ជនរងគ្រោះជាបុរស ៥នាក់ ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ១នាក់ និងស្ត្រី ១នាក់
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖
  - ការលេងច្នៃគ្រាប់ ២នាក់
  - ការរកស្បៀងអាហារ ២នាក់
  - ការធ្វើសកម្មភាពយោធា ១នាក់
  - ការសម្អាតដីសម្រាប់ធ្វើកសិកម្ម ១នាក់
  - ការធ្វើកសិកម្ម ១នាក់។

## 6- ផលប៉ះពាល់នៃតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២២ ដល់ខែឧសភា ឆ្នាំ២០២៣ (ជនរងគ្រោះ ៦០នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៥% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៧៥% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៧% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

## ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងខែឧសភា ឆ្នាំ២០២៣
## ឧប្បត្តិហេតុ ៨ករណី ជនរងគ្រោះ ៧នាក់




ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ2020 ដល់ខែឧសភា ឆ្នាំ2023

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2020** | **3** | **3** | **6** | **7** | **13** | **6** | **7** | **7** | **3** | **0** | **5** | **5** | **65** |
| *ការបូកបណ្តាក់ ឆ្នាំ2020* | *3* | *6* | *12* | *19* | *32* | *38* | *45* | *52* | *55* | *55* | *60* | *65* | |
| **2021** | **6** | **5** | **2** | **8** | **5** | **0** | **4** | **3** | **1** | **8** | **0** | **2** | **44** |
| *ការបូកបណ្តាក់ ឆ្នាំ2021* | 6 | 11 | 13 | 21 | 26 | 26 | 30 | 33 | 34 | 42 | 42 | 44 | |
| *ការប្រែប្រួលភាគរយ 2020 ធៀប 2021* | 100 | 83 | 8 | 11 | -19 | -32 | -33 | -37 | -38 | -24 | -30 | -32 | |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2021* | 5 | 4 | 5 | -1 | 0 | 1 | -4 | -3 | -1 | -8 | 0 | -1 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2021* | 83 | 80 | 250 | -13 | 0 | 100 | -100 | -100 | -100 | -100 | 0 | -50 | |
| *ការបូកបណ្តាក់ ឆ្នាំ2022* | ***11*** | ***20*** | ***27*** | ***34*** | ***39*** | ***40*** | ***40*** | ***40*** | ***40*** | ***40*** | ***40*** | ***41*** | |
| *ការប្រែប្រួលភាគរយ 2021 ធៀប 2022* | 83 | 82 | 108 | 62 | 50 | 54 | 33 | 21 | 18 | -5 | -5 | -7 | |
| **2023** | **3** | **5** | **4** | **0** | **7** | | | | | | | | **19** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2022* | -8 | -4 | -3 | -7 | 2 | | | | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2022* | -73 | -44 | -43 | -100 | 40 | | | | | | | | |
| *ការបូកបណ្តាក់ ឆ្នាំ2023* | ***3*** | 8 | ***12*** | 12 | ***19*** | | | | | | | | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | | | | | | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀតនឹងស្រាវជ្រាវឲ្យទាន់ពេលវេលា ដែលជាផ្នែកមួយនៃដំណើរការប្រមូលទិន្នន័យ



# ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ2022 ដល់ខែឧសភា ឆ្នាំ2023

## រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ2022 និងឆ្នាំ2023

| | មករា22 | កុម្ភៈ22 | មីនា22 | មេសា22 | ឧសភា22 | មិថុនា22 | កក្កដា22 | សីហា22 | កញ្ញា22 | តុលា22 | វិច្ឆិកា 22 | ធ្នូ22 | សរុប2022 | មករា23 | កុម្ភៈ23 | មីនា23 | មេសា23 | ឧសភា23 | មិថុនា23 | កក្កដា23 | សីហា23 | កញ្ញា23 | តុលា23 | វិច្ឆិកា 23 | ធ្នូ23 | សរុប2023 | សរុប | ការបូកបណ្ដាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្ដាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2022-2023** | | | |
| ព្រះវិហារ | 6 | 0 | 2 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **12** | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **13** | 13 | 21.7 | 22 |
| បាត់ដំបង | 2 | 0 | 3 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **7** | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **9** | 22 | 15 | 37 |
| កំពង់ធំ | 1 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **5** | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **6** | 28 | 10 | 47 |
| ឧត្ដរមានជ័យ | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | **3** | 0 | 1 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **6** | 34 | 10 | 57 |
| ស្វាយរៀង | 0 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **5** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **5** | 39 | 8.3 | 65 |
| ពោធិ៍សាត់ | 1 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **5** | 44 | 8.3 | 73 |
| រតនៈគិរី | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **4** | 48 | 6.7 | 80 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **3** | 51 | 5 | 85 |
| សៀមរាប | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **3** | 54 | 5 | 90 |
| ក្រចេះ | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **2** | 56 | 3.3 | 93 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 57 | 1.7 | 95 |
| តាកែវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 58 | 1.7 | 97 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 59 | 1.7 | 98 |
| ព្រះសីហនុ | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 60 | 1.7 | 100 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| កណ្ដាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 60 | 0 | 100 |
| សរុប | 11 | 9 | 7 | 7 | 5 | 1 | 0 | 0 | 0 | 0 | 0 | 1 | **41** | 3 | 5 | 4 | 0 | 7 | 0 | 0 | 0 | 0 | 0 | 0 | 0 | **19** | **60** | | | |



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែឧសភា ឆ្នាំ2023

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | ព្រះវិហារ | 11 | 2 | **13** | 13 |
| 2 | បាត់ដំបង | 2 | 7 | **9** | 22 |
| 3 | កំពង់ធំ | 0 | 6 | **6** | 28 |
| 4 | ឧត្តរមានជ័យ | 5 | 1 | **6** | 34 |
| 5 | ពោធិសាត់ | 4 | 1 | **5** | 39 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែឧសភា ឆ្នាំ2023

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 11 | 2 | **13** | 13 |
| 2 | ស្វាយរៀង | ស្វាយរៀង | 0 | 5 | **5** | 18 |
| 3 | វាលវែង | ពោធិសាត់ | 4 | 1 | **5** | 23 |
| 4 | អន្លង់វែង | ឧត្តរមានជ័យ | 3 | 1 | **4** | 27 |
| 5 | សំឡូត | បាត់ដំបង | 0 | 4 | **4** | 31 |
| 6 | អូរយ៉ាដាវ | រតនៈគិរី | 0 | 4 | **4** | 35 |
| 7 | បារាយណ៍ | កំពង់ធំ | 0 | 4 | **4** | 39 |
| 8 | ថ្មពួក | បន្ទាយមានជ័យ | 2 | 0 | **2** | 41 |
| 9 | រតនៈមណ្ឌល | បាត់ដំបង | 0 | 2 | **2** | 43 |
| 10 | គាស់ក្រឡ | បាត់ដំបង | 1 | 1 | **2** | 45 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែឧសភា ឆ្នាំ2023

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 6 | 1 | **7** | 7 |
| 2 | សង្ខោរ | ស្វាយរៀង | ស្វាយរៀង | 0 | 5 | **5** | 12 |
| 3 | គគីរធំ | បារាយណ៍ | កំពង់ធំ | 0 | 4 | **4** | 16 |
| 4 | យ៉ាទុង | អូរយ៉ាដាវ | រតនៈគិរី | 0 | 4 | **4** | 20 |
| 5 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្តរមានជ័យ | 2 | 1 | **3** | 23 |
| 6 | អន្លង់រាប | វាលវែង | ពោធិសាត់ | 2 | 1 | **3** | 26 |
| 7 | គោករមៀត | ថ្មពួក | បន្ទាយមានជ័យ | 2 | 0 | **2** | 28 |
| 8 | រស្មីសង្ហារ | រតនៈមណ្ឌល | បាត់ដំបង | 0 | 2 | **2** | 30 |
| 9 | សំឡូត | សំឡូត | បាត់ដំបង | 0 | 2 | **2** | 32 |
| 10 | សំរិល | សំឡូត | បាត់ដំបង | 0 | 2 | **2** | 34 |

បពជមក
ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

# ការផ្ទុះបញ្ជាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេលៈ មករា ឆ្នាំ2022 - ឧសភា ឆ្នាំ2023

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍ៈ 60

## ការបែងចែកតាមប្រភេទយុទ្ធភណ្ឌគ្រឿងផ្ទុះ




## មូលហេតុបណ្តាលឲ្យរងគ្រោះ




## លក្ខណៈនៃអ្នករងគ្រោះ




## ការផ្ទុះបញ្ជាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

អំឡុងពេលៈ ខែមករា ឆ្នាំ2022 - ខែឧសភា ឆ្នាំ2023

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍ៈ 60

## សកម្មភាពដែលបណ្តាលឲ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 42 | 2 | 16 | 60 |




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្តាលឲ្យផ្ទុះមីន

27




### សកម្មភាពដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

33




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

